**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការពារជាតិ**

# សារថ្វាយព្រះពរ

**សូមក្រាបបង្គំទូលថ្វាយ**
**សម្តេចព្រះមហាក្សត្រី នរោត្តម មុនីនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ**
**ក្នុងសេរីភាពសេចក្តីថ្លៃថ្នូរ និងសុភមង្គល ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់**

ក្នុងឱកាសដ៏នក្ខត្តឫក្ស នៃទិវា **បុណ្យចូលឆ្នាំសកល ឆ្នាំ ២០១៦** នេះ ទូលព្រះបង្គំជាខ្ញុំទាំងអស់គ្នា ក្នុងនាមថ្នាក់ដឹកនាំក្រសួងការពារជាតិ ព្រមទាំងនាយទាហាន នាយទាហានរង និងពលទាហាន នៃកងយោធពលខេមរភូមិន្ទទាំងមូល សូម **សម្តេច ព្រះមហាក្សត្រី** ទ្រង់ព្រះមេត្តាប្រោសព្រះបរមរាជានុញ្ញាតឲ្យទូលព្រះបង្គំជាខ្ញុំទាំងអស់គ្នា សូមសម្តែងនូវកតញ្ញូកតវេទិតាធម៌ដ៏ខ្ពង់ខ្ពស់បំផុតថ្វាយចំពោះ ព្រះមហាករុណាទិគុណនៃ **សម្តេច ព្រះមហាក្សត្រី** ដែលទ្រង់បានគង់ប្រថាប់នៅជាមួយដល់កូនចៅ និងប្រោសព្រះរាជទានទាំងព្រះកាយពល ព្រះបញ្ញាញាណ និងព្រះរាជទ្រព្យផ្ទាល់របស់ព្រះអង្គជាច្រើន ក្នុងបុព្វហេតុមនុស្សធម៌ជួយដល់ប្រជាពលរដ្ឋទីទ័លក្រ និងប្រជាពលរដ្ឋរងគ្រោះដោយសារគ្រោះធម្មជាតិផ្សេងៗ។

ក្នុងឱកាសដ៏ថ្លៃថ្លានេះ ទូលព្រះបង្គំជាខ្ញុំទាំងអស់គ្នា សូមលំឱនកាយវាចាចិត្តបួងសួងចំពោះគុណបុណ្យព្រះរតនត្រ័យ ព្រមទាំងវត្ថុស័ក្តិសិទ្ធិទាំងឡាយក្នុងលោក មានទេវតារក្សាព្រះមហាស្វេតច្ឆត្រ ព្រមទាំងព្រះរាជតេជបារមី នៃព្រះអតីត ព្រះមហាក្សត្រ ព្រះមហាក្សត្រីយានីខ្មែរគ្រប់ព្រះអង្គ ជាពិសេសព្រះបរមសពព្រះបរមរតនកោដ្ឋ សូមទ្រង់ព្រះមេត្តាប្រោសព្រះរាជទាននូវ ព្រះរាជស័ព្ទសាធុការពរជ័យ បវរសួស្តី សិរីមង្គល វិបុលសុខ មហាប្រសើរ ថ្វាយចំពោះ **សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល** ជាទីគោរពសក្ការៈ សូមព្រះអង្គទ្រង់ប្រកបដោយព្រះរាជសុខភាពល្អបរិបូរណ៍ ព្រះជន្មាយុយឺនយូរ ដើម្បីព្រះអង្គទ្រង់គង់ប្រថាប់នៅជាម្លប់ដ៏ត្រជាក់ក្សេមក្សាន្តដល់ទូលព្រះបង្គំជាខ្ញុំទាំងអស់គ្នា និងប្រជាពលរដ្ឋកម្ពុជា ជាកូន ជាចៅ ចៅទួត របស់ព្រះអង្គអស់កាលជានិច្ចនិរន្តរ៍តរៀងទៅ។

សូម **សម្តេច ព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល** ជាទីគោរពសក្ការៈ ទ្រង់ព្រះមេត្តាទទួលនូវគារវភក្តីភាពដ៏ខ្ពង់ខ្ពស់បំផុតអំពីទូលព្រះបង្គំជាខ្ញុំទាំងអស់គ្នា។

សេចក្តីគួរពុំគួរ សូមទ្រង់ព្រះមេត្តាប្រោស ។

សូមក្រាបបង្គំទូលថ្វាយនៅរាជធានីភ្នំពេញ ថ្ងៃទី១៧ ខែ [illegible] ឆ្នាំ ២០១៥

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ**

នាយឧត្តមសេនីយ៍ **ទៀ បាញ់**

វិថីហ្សកឌីមីត្រូវ សង្កាត់មិត្តភាព ខណ្ឌ៧មករា រាជធានីភ្នំពេញ ទូរស័ព្ទ-ទូរសារៈ ០២៣ ៨៨៣ ២៧៤ អ៊ីមែលៈ Generalsec@mod.gov.kh